ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

*លើកទី៣*

# កិច្ចព្រមព្រៀង

*រវាង*

ក្រុមហ៊ុន វ៉ាយ អិល ធី អ៊ិនធើណេសិនណល ខូអិលធីឌី

*និង*

តំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុន វ៉ាយ អិល ធី អ៊ិនធើណេសិនណល ខូអិលធីឌី

ស្តីពី

**ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារដោយមូលហេតុគ្មានការបញ្ជាទិញ**

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង៩:០០នាទីព្រឹក នៅក្រុមហ៊ុន វ៉ាយ អិល ធី អ៊ិនធើណេសិនណល មានទីតាំងនៅភូមិសទ្ធា ឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង បានរៀបចំកិច្ចប្រជុំរវាងនាយកក្រុមហ៊ុននិងតំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុន។

នៅក្នុងអង្គប្រជុំនាយកក្រុមហ៊ុន បានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនប្រឈមនិងវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរដោយសារគ្មានការបញ្ជាទិញ។ ម្យ៉ាងវិញទៀតក្រុមហ៊ុនមានអ្នកបញ្ជាទិញតែមួយប្រទេសគត់គឺប្រទេសជប៉ុន ដែលជាហេតុធ្វើអោយកម្មករនិយោជិតគ្មានការងារធ្វើតម្រូវអោយមានការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន**<u>៦៩</u>**នាក់(<u>ស្រី**២០**</u>) ក្នុងចំណោមកម្មករនិយោជិត<u>សរុប **៣៣៨**</u>នាក់(<u>ស្រី**១៨៥**</u>) រយៈពេល៣០ថ្ងៃ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារភាគីទាំងពីរឯកភាពគ្នាដូចខាងក្រោម ៖

ប្រាក់ឧបត្ថម្ភពីនិយោជកចំនួន **៧០** ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល១ខែ <u>ដោយគិតចាប់ពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ចូលធ្វើការវិញនៅទី២៤ ខែតុលា ឆ្នាំ២០២៣</u> ការបើកប្រាក់ឧបត្ថម្ភនៅថ្ងៃទី១០ ដល់ថ្ងៃ១៥ នៃខែបន្ទាប់ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង៩និង៣០នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល ភាគីទាំងពីរបានឯកភាពគ្នាដោយមានការយោគយល់គ្នា សហការគ្នា ក្រោមស្មារតីទទួលខុសត្រូវ។

ធ្វើនៅព្រៃវែងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៣

ស្នាមម្រាមដៃតំណាងកម្មករនិយោជិត

គង់ សុវណ្ណា សេរី រតនា សៀក យ៉ា ហែម ភ័ស្ស ខេវ ខេមាលាវី

នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន វ៉ាយអិលធី អ៊ិនធើណេសិនណល YLT INTERNATIONAL CO., LTD. KINGDOM OF CAMBODIA

KANG JONG KYU